- ខ្ញុំពុំនឹកស្មានថា លោកគ្រូមានគូប្រចាំជីវិតហើយដូច្នេះសោះ ។ ខ្ញុំអង្គុយលេងយប់ព្រលប់ជាមួយប្ដីគេដូច្នេះ ជាការមួយមិនល្អទាល់តែសោះ !

ថាហើយនាងក្រោក... តែខ្ញុំចាប់ដៃជាប់ ។ សម្លេងខ្ញុំស្រាប់តែញ័រ ..... ចង់និយាយមិនចេញ ....

- ខ្ញុំឆ **កែវ** ទេ.... ឱ តែប៉ុណ្ណឹងខ្ញុំដឹងថា **កែវ** មិនស្អប់ខ្ញុំទេ ហើយខ្ញុំជឿថាកែវមិនបដិសេធ នៅពេលដែលខ្ញុំលាតត្រដាងពីចិត្តខ្ញុំពិតៗ ជម្រាបកែវ !

នាងនៅស្ងៀមហាក់ដូចកំពុងគិត, កំពុងស្ទង់ បីដូចគេស្ទង់ដំណើរដែលចូលទៅក្នុងក្ដីសាហាវមួយគួរឱ្យខ្លាច ។ ការស្ងប់ស្ងៀមរបស់នាង ធ្វើខ្ញុំស្ទើរផុតដង្ហើម......

- ខ្ញុំស្រឡាញ់កែវណាស់... ចង់នៅជិតកែវ !

នាងនៅស្ងៀមទៀត ។ ខ្ញុំហេលហាលក្នុងចិត្តអស់សង្ឃឹម ។

- ប្រហែល **កែវ** យល់ថាខ្ញុំព្រហើន ពុំគប្បីចំពោះ **កែវ** ហើយហ៊ានលួចស្រឡាញ់ **កែវ** ដែលមានគុណ, ដែលចិត្តល្អបំផុតចំពោះខ្ញុំ ។ ទោះម្ដេចម្ដាសូម **កែវ** អភ័យទោសផងណា !



នេះជាចិត្តពិតៗរបស់ខ្ញុំ ។ ឱ ស្អែកនេះខ្ញុំក្រោកពីព្រលឹមចាកចេញពីទីនេះហើយ ដើម្បីកុំឱ្យខ្ញុំមានកំហុសជាលើកទីពីរទៀតចំពោះ **កែវ** ! ពីថ្ងៃនេះទៅខ្ញុំមានតែទុក្ខទេ....

កែវឈ្ងោកមុខចុះ នាងស្រក់ទឹកភ្នែកតក់ៗ ធ្វើឱ្យខ្ញុំមានការខ្វល់ចិត្តរឹតតែខ្លាំង ។

- **កែវ** ដឹងរឿងនេះតែម្នាក់ឯងបានហើយ ! ទុកដូចជាការខុសឆ្គងរបស់ខ្ញុំមួយចំពោះ **កែវ** ទៅចុះ ខ្ញុំជឿថា **កែវ** ដែលមានចិត្តល្អវិសេស អាចប្រណីទោសដល់ខ្ញុំមិនខាន។ ស្អែកនេះខ្ញុំលាកែវហើយ.... ខ្ញុំទៅដល់ភ្នំគូលែន ហើយសម្ងំនៅទីនោះរហូតពេលបញ្ចប់ការស្រាវជ្រាវរបស់ខ្ញុំ.....

នាងមិនបាត់យំសោះ ។ មិនដឹងថានាងយំដោយខឹងនឹងខ្ញុំឬយ៉ាងណាទេ ។ បើសិនជា **ផូនម៉ែន** ឃើញនាងយំដូច្នេះតើគាត់នឹងខកចិត្តនឹងខ្ញុំយ៉ាងណា ? ខ្ញុំមុខតែអស់លក្ខណ៍នៅល្ងាចនេះហើយ ។

- ខ្ញុំអង្វរ **កែវ** ! រឿងអ្វីៗ ខ្ញុំទទួលខុសទាំងអស់....

កែវងើបមុខឡើងប្រកបដោយទឹកភ្នែករហាម ។ នាងគ្រវីក្បាលដោយមិនយល់សោះថា តើនាងចង់បញ្ជាក់ពីរឿងអ្វី

ទោះបីខ្ញុំបង្ហាញទឹកមុខទទួលខុសយ៉ាងណា ក៏ កែវ នៅតែគ្រវីក្បាលដដែល ។ នាងចាប់ដៃខ្ញុំ .... ដែលដៃនាងញ័រៗ...

- បង !....

ខ្ញុំធ្មេចភ្នែក ហាក់មិនចង់ជឿដល់ត្រចៀកខ្ញុំសោះ ។ តើត្រចៀកខ្ញុំមានសំណាងបានស្តាប់ពាក្យដ៏ពិរោះឬ ?

- បង វ៉ាត !

- ហើយនាងលើកដៃខ្ញុំទៅថើប .... រួចញញួញក់នឹងមុខនាង ។ ខ្ញុំហាក់ដូចជានៅលើស្ថានតុសិតដ៏មានបុណ្យបារមីផុតមនុស្សឬទេវតា ។

- អូន កែវ ! កែវ របស់បង ! កែវ ដួងព្រលឹង. កែវ ថ្លើមថ្លៃជីវិតបង ! អូនធ្វើឱ្យបងមានសង្ឃឹមហើយមែនទេ ?

សេចក្តីសង្ស័យ បារម្ភ បញ្ហារាប់រយពាន់ជំពូក ដោះស្រាយរួចតាមរយៈពាក្យដ៏ស្រទន់ពីរឃ្លា "បង វ៉ាត ! អូន កែវ!" អ្វីៗក៏ដូចជាធូរស្រាលទាំងអស់ ទាំងគំនិតប្រាជ្ញាស្មារតីទាំងធម្មជាតិនានានៅជុំវិញ ។

វាយោបក់រំភើយៗ ធ្វើឱ្យគូស្នេហ៍ទាំងពីរ រីកបេះដូងសប្បាយរីករាយឥតឧបមា ។ គ្មានអ្វីប្រសើរជាងស្នេហាថ្មោងថ្មីហើយយល់ចិត្តគ្នាទេ ។



ព្រះចន្ទ្រជិតពេញវង់ ជះពន្លឺរស្មីដ៏មនោរម្យចន្លោះស្លឹកឈើ ចាំងមុខអូន កែវ ធ្វើឱ្យបេះដូងយុវជនពុះកញ្ជ្រោលស្ទើរទប់ចិត្តមិនបាន ។ ចង្រិតដែក ចង្រិតខ្មៅស្រែកយំច្រេកៗតាមជួររបង ហាក់ដូចជាជូនពរដល់គូសង្សារថ្មី ។ សត្វចិញ្ចឹមព្រាប ពពែ ក្ងោក ពុំបានធ្វើចលនាឬបញ្ចេញសំឡេងដូចពេលថ្ងៃឡើយ ។ ពួកវាសម្ងំយ៉ាងស្ងៀមស្ងាត់ ហាក់ដូចជារង់ចាំស្តាប់ការសន្ទនា រវាងកំលោះ-ក្រមុំដែលទើបតែចុះសម្រុងនិងយោគយល់ចិត្តគ្នា ។

ធម្មជាតិនិងស្នេហាដោយសារក្តីរំភើបខ្លាំងផង អរផងស្រឡាញ់ផង ស្រីគ្រប់លក្ខណ៍នឹកទឹកភ្នែក នៅចំពោះមុខបុរសដែលនាងស្រឡាញ់ ។ ចំជាត្រូវមែន ។

អូន កែវ នៅស្ងៀម មិនដឹងជានាងគិតដល់ណាទេ តែខ្ញុំឯណេះគិតរិះរកពាក្យពេចន៍មកនិយាយសច្ចា ដើម្បីឱ្យមានន័យជាងសំដីនាង.....

- ពីនេះតទៅមុខ ជីវិតនឹងមានរស្មីភ្លឺចិញ្ចែងចិញ្ចាចហើយ ! អូនធ្វើឱ្យបងមានសង្ឃឹមច្រើនណាស់ !

មួយសន្ទុះសត្វព្រាបដែលដេកនៅលើប្រគាបផ្ទះ ទទះ

ស្លាបតិចៗ ដោយវាលង់ដំណេកហើយភ្លាត់ជើងធ្លាក់ក៏មិនដឹង យើងភ្ញាក់អារម្មណ៍មកវិញ.... ដែលខ្ញុំតឿននាងថា :

- យប់ជ្រៅហើយ ! អូនទៅគេងចុះ ជីវិតយើងមានរស្មីហើយ......ថ្ងៃស្អែកនឹងមានរឿងល្អៗ សម្រាប់យើងទៀត. ថ្ងៃស្អែកនឹងមានចំរៀងដ៏ពិរោះ មានផ្កាដ៏ក្រអូបសម្រាប់យើងទៀត ។ អូនទៅគេងចុះ គេងសង្ឃឹមថ្ងៃស្អែកដែលនាំមកនូវសុបិនដ៏ប្រណីតសម្រាប់យើង......

នាងអង្អែលបបូរមាត់ខ្ញុំ.....

- បងជាកវីនិពន្ធ....

- សម្រាប់តែអូនមួយប៉ុណ្ណោះ ។ ក្រៅពីអូនប្រហែលបងនិយាយមិនចេញទេ ......

..................................................................

ស្នេហ៍ពណិមាសនៃយើងខ្ញុំ បានចាប់ផ្ដើមក្រោមពន្លឺព្រះច័ន្ទដ៏ស្រទន់នៃរដូវផ្ការីក ។ ស្នេហានេះធ្វើឱ្យខ្ញុំប្រែផ្លាស់យ៉ាងច្រើនតាំងពីគំនិតអាកប្បកិរិយា. ហើយព្យាយាមប្រព្រឹត្តអ្វីដែលល្អ ប្រសើរ ដើម្បីតែមយ៉ាងប៉ុណ្ណោះ គឺផ្គាប់ចិត្តអូន កែវដ៏ពិសិដ្ឋរបស់ខ្ញុំ ។ សេចក្ដីសង្ឃឹមរបស់ខ្ញុំក៏លេចឡើង ហើយ



ទិសដៅទៀតសោតក៏វែងឆ្ងាយផូរផង់ ។

យប់នេះខ្ញុំគេងពុំលក់សោះ... ខ្ញុំក្រោកឡើងទល់បង្អួចមើលកន្លែងដែលយើងសារភាពស្នេហា កាលពីមុននេះបន្តិច. ហើយមើលទៅក្រៅ ។ រហាត់ទឹកនៅតែវិល ...ស្នេហាខ្ញុំអាចនឹងរលត់ទៅបាត់ លុះត្រាតែរហាត់ឈប់វិលដែរ ។ តែកាលណា ? រហាត់វិលមិនឈប់សោះ....យប់ថ្ងៃ...រាល់ខែ រាល់រដូវនៅតែវិលជាដរាប ។ ខ្ញុំមិនដែលអត់ងងុយដល់ថ្មើរនេះទេ ។ តែយប់នេះ ខ្ញុំចង់តែអង្គុយមើល ហើយស្រមៃដល់អ្វីៗដែលល្អ ហើយដែលយើងខ្ញុំពុំទាន់បានជួបប្រទះសោះ តើអូន កែវ កំពុងគេងនៅបន្ទប់ដែលឃ្លាតពីខ្ញុំ តែពីរបីម៉ែត្រសោះ.... នាងគេងមិនលក់ដូចខ្ញុំដែរឬអ្វី ?

គួរឱ្យអស្ចារ្យណាស់ ខ្ញុំរសាត់ព្រាត់តាំងពីកម្ពុជាក្រោមចុងនគរម្ខាង..... ស្រាប់តែមកជួបកញ្ញាស្រស់ នៅសៀមរាបដែនដីម្ខាងឯណេះ .... តើនេះជាវាសនាឬចៃដន្យ?

មិនស្មានថា ដូនម៉ែន បានដឹងរឿងរ៉ាវយើងទាំងពីរនៅយប់នេះសោះ ...... ។

# ៤

# ស្នេហ៍ពិសិដ្ឋនៃយើង

កែវ បាននាំរឿងរ៉ាវស្រុះចិត្តរវាងខ្ញុំនិងនាង ទៅប្រាប់មេដោះនាង..... គេដឹងស្ទើរតែគ្រប់គ្នា....

ដួនម៉ែន ហៅខ្ញុំទៅសួរបញ្ជាក់ទៀត ដូចចៅក្រមសួរចម្លើយកូនក្ដី...ទីបំផុតគាត់ក៏យល់ចិត្តខ្ញុំប្រហែលកាន់តែច្បាស់ហើយមើលទៅ ។

- ក្មួយឃើញស្រាប់ .... (ដួនម៉ែន និយាយមកកាន់ខ្ញុំ) កែវ កំព្រាគួរឱ្យអាណិតណាស់ ។ បើក្មួយធ្វើឱ្យ កែវ ខកចិត្តឬធ្វើឱ្យមានរឿងអាក្រក់ដល់ កែវ ក្មួយមិនបាច់មកជាន់ទីនេះទៀតទេ !

- នរណាឡើយក៏នឹងដាច់ចិត្ត បោកប្រាស កែវ កើតនោះ ? ខ្ញុំយកកេរឈ្មោះខ្ញុំជាកសិណ ។ បំណាច់នឹងខ្ញុំមានវាសនាបានជួប កែវ ហើយ ខ្ញុំនឹងខំកសាងខ្លួនឱ្យប្រសើរដូច



កែវ ហើយដើម្បីតែ កែវ មួយប៉ុណ្ណោះ !

ដួនម៉ែន ស្ងៀមមួយស្របក់ ទើបបន្តថា :

- រឿងនេះ ! វានៅសល់តែខាងក្មួយទេ ដែលត្រូវរកចាស់ទុំមកចូលស្ដីដណ្ដឹងតាមដំណើរ ។ ខាង កែវ ឯណេះមានអ៊ុំនិងចាស់ៗជិតខាង ជាអ្នកមើលការខុសត្រូវលើ កែវ មើល៍? ថ្ងៃណាក្មួយអាចឱ្យចាស់ទុំ ចូលមកសម្រេចរឿងនេះ ?

ខ្ញុំឱនមុខចុះមានកង្វល់ជាខ្លាំង ។ តើខ្ញុំរកនរណា ? ឱព្រះអើយ! រូបខ្ញុំអីក៏ខុសគេម្ល៉េះ ?នឹកឡើងខ្ញុំចង់តែទ្រហោយំ

- ដូចខ្ញុំជម្រាបលោកអ៊ំពីមុនមកហើយថា ខ្ញុំជាកូនកំព្រា សូម្បីតែបងប្អូនសាច់ញាតិជិតឆ្ងាយមីងមា ក៏គ្មានដែរ ។ ខ្ញុំនេះរស់នៅត្រមង់ត្រមោចម្នាក់ឯង .... គឺមានតែចិត្តបរិសុទ្ធស្អាតប៉ុណ្ណោះ ជាបណ្ណាការចូលស្ដីដណ្ដឹង កែវ !

ដួនម៉ែន ឈប់ស្ងៀមហាក់ដូចជាយល់ចិត្តខ្ញុំ ។ ខ្ញុំបន្តទៀតថា :

- ខ្ញុំសុំក្ដីករុណាពីលោកអ៊ំ សូមលោកអ៊ំមេត្តាសម្រួលរឿងនេះ តាមដំណើរផងចុះ ។ ខ្ញុំស្រឡាញ់ កែវ នឹងចិត្តស្មោះជីវិត....

ម្ជូនម៉ែន ដកដង្ហើមធំ ... និយាយទាំងមិនដាច់ស្រេច ។

- ពិបាកដែររឿងនេះ !

- លោកអ៊ំ ! លោកអ៊ំជាមេបាចាស់ទុំខ្ញុំហើយ ។ ខ្ញុំសូមអង្វរ សូមលោកអ៊ំមេត្តាសម្រួលរឿងនេះដោយអនុគ្រោះផងទៅចុះ ព្រោះខ្ញុំពុំអាចរស់នៅដោយបែកពី កែវ បានទេ ...

- អីចឹងក្មួយគិតរៀបចំខែណា ?

សម្ដីនេះធ្វើឱ្យខ្ញុំមានសង្ឃឹមព្រើតឡើងវិញ ។ ខ្ញុំជ្រួញចិញ្ចើមងើបទៅលើ. តែគិតមិនចេញ ។

- សូមលោកអ៊ំជួយគិតគូរផងចុះ តើថ្ងៃណា ខែណាអាចនឹងសមរម្យ ។

ម្ជូនម៉ែន គិតមួយស្របក់ទើបចាប់រៀបរាប់ដូចតាហោរាវាយលេខអត្ថៈថា :

- ខែនេះ គឺភទ្របទ.....រួចហើយអស្សុជ ..... រៀបខែកត្តិកនេះមិនទាន់ទេ ។ ពេលល្អដល់ខែផល្គុន. តែខែផល្គុនក្តៅណាស់ ......

ខ្ញុំនឹកចង់អស់សំណើច ។ ចាស់ៗ ចេះគិតគន់ដឹងទុក្ខធុរៈណាស់ហ្ន៎...។ គាត់ចាប់រៀបរាប់តទៅទៀត :



- ពេលល្អមានតែខែពិសាខ...។ ហ្នឹងហើយរៀបចំខែពិសាខ ?

- បាទ ! ខ្ញុំត្រេកអរណាស់ ។ ដល់ពេលនោះខ្ញុំនឹងចេញធ្វើការល្មមដែរ ......

- ឥឡូវសម្រេចថាយកខែពិសាខចុះ ចាំអ៊ំទៅរកគ្រូមើលយកថ្ងៃល្អមានពេលាទៀត ។

ខែពិសាខ.... នៅបាំងយូរខែទៀតដែរ ។ គ្មានអ្វីអាចវាស់ទំហំចិត្តកំឡោះឬក្រមុំស្រឡាញ់គ្នាជក់ចិត្ត ហើយទទួលអនុគ្រោះពីមាតាបិតានឹងផ្សំផ្គុំគ្នាប្តីប្រពន្ធ ។

ខ្ញុំសំណាក់ផ្ទះ ម្ជូនម៉ែន ដដែល ។ អូន កែវ ដាំបាយស្លស្លុកសម្រាប់ខ្ញុំរាល់ពេល ។ នាងនិងខ្ញុំ ហាក់ដូចជាប្តីប្រពន្ធរួចហើយដូច្នេះ បើគេឃើញពីក្រៅមក ។ តែខ្ញុំបានរក្សាទុកនូវកិត្តិយសល្អចំពោះ កែវ ជានិច្ច ។ អូន កែវ មានពូជអំបូរខ្ពង់ខ្ពស់ ក្រអូបសុះសាយណាស់ ! បើសិនជានាងមានផុលរមាស់ដោយសារខ្លួនខ្ញុំ.... ខ្ញុំស្លាប់ទៅវិញជាជាង ។

នាងនៅតែជាកូនសិស្សខ្ញុំដដែល ហើយជាសង្សារឬគូដណ្តឹងរបស់ខ្ញុំទៀតផង ។ ទោះបីយើងពុំទាន់លើកជំនូនស៊ីស្លា

ភ្ជាប់ពាក្យក៏ដោយ ក៏បេះដូងយើងហាក់ដូចជាឆ្នាក់កូចរណ្តំគ្នាជាស្រេចទៅហើយ ។ ពេលណានាងទំនេរ នាងតែងជួយចម្លងនិក្ខេបទរបស់ខ្ញុំ ដែលខ្ញុំជាអ្នកហៅ រួចនាងជាអ្នកសរសេរតាមសូត្រ ។ សល់ពេលពីរៀន សល់ពេលពីចម្លងនិក្ខេបបទ យើងជជែកគ្នាលេង ញញឹមស្រស់ស្រាយពេញចិត្តនឹងវាសនាខ្លួន ។ យើងឧស្សាហ៍និយាយគ្នាលេង រហូតយប់ជ្រៅនៅក្រោមដួងខែរហូតដល់ព្រះចន្ទយាងគងភ្នំ ហើយលិចបាត់សន្លឹមនៅឯនាយផែនដី ។ ព្រះចន្ទលិចទៅមែន តែស្នេហាយើងនៅតែរះខ្ពស់ត្រដែតក្នុងដួងចិត្ត ។ យើងទាំងពីរកំពុងបោះជំហានជាមួយគ្នាលើដងផ្លូវស្នេហាមួយដ៏បរិសុទ្ធ ។ យើងកំពុងបញ្ចូលនៅក្នុងប្រអប់ទ្រូងនូវថាមពលពិសិដ្ឋនេះ ។ តន្ត្រីស្នេហ៍លាន់រងំយ៉ាងចាប់ចុងចួន ក្នុងអារម្មណ៍យើងទាំងពីរ ...... ព្រលឹងទាំងនេះហាក់អណ្តែតព្រមៗ គ្នា ទៅដល់ទីមួយដ៏មនោរម្យ ។

ភ្នែកអូន កែវ ភ្លឺថ្លា ហើយខៀវស្រទន់ ដូចផ្ទៃមេឃនៃរដូវរំហើយ. ហើយបេះដូងទាំងពីរ ពោរពេញទៅដោយកំណាព្យដ៏ពិរោះមិនចេះចប់ ដូចជាឈាមចេញពីបេះដូងមិនចេះអស់. ស្រោចមកលើសព្វសរសៃ..... ។



យើងជាសង្សារដែលស្រឡាញ់គ្នា បែកគ្នាមិនបាន ។ ដោយសារស្នេហានេះ ខ្ញុំបានប្រែផ្លាស់អស់រលីងនូវអ្វីៗ ដែលខ្ញុំមានពីមុនមក ទាំងគំនិតរវើរវាយ ទាំងអាកប្បកិរិយាពុំគប្បីខ្លះ ។ ខ្ញុំប្រទះឃើញអ្នកខ្លះ យកអំណាចទៅជិះជាន់គ្នា មើលងាយគ្នា. កេងប្រវ័ញ្ចលើគ្នា...បើជាខ្ញុំវិញ ខ្ញុំនឹងខ្មាសអូន កែវស្លាប់ហើយ ព្រោះអូន កែវ មិនចូលចិត្តអំពើបែបនោះទេ ។ ខ្ញុំមិនដែលឮអូន កែវ និយាយអាក្រក់ពីនរណា ហើយចិញ្ចឹមចិត្តសងសឹកនឹងនរណាសោះ ។ គឺមានតែខ្ញុំទេដែលបញ្ចេញកំហឹងខ្លះដាក់អូន កែវ ពេលខ្ញុំប្រទះអំពើអាក្រក់អ្វីមួយ ដូចជាឃើញនាម៉ឺន អ្នកកាន់អំណាច កំហែងលើអ្នកស្លូតត្រង់ជាដើម ។ កាលណាខ្ញុំនិយាយរឿងនេះ អូន កែវ តែងតែអង្អែលបបូរមាត់ខ្ញុំដោយពាក្យស្រទន់ថា :

- "អូនពេញចិត្តនឹងបង ព្រោះបងមិនកំរោលដូចជាគេនោះ ហើយអូនជឿថា បងនឹងចេះប្រើអំណាចដោយត្រឹមត្រូវបើសិនថ្ងៃក្រោយបងមានអំណាច ។ សំណាងអូនណាស់បានជួបបង ដែលមានវិចារណញ្ញាណល្អប្រសើរយ៉ាងនេះ...."

ប្រាសាទតាព្រហ្ម បាយ័ន បក្សីចាំក្រុង បារាយណ៍ទឹក

ថ្ងា ជាសាក្សីនៃសេចក្ដីស្នេហាដ៏ពិសិដ្ឋនៃយើងខ្ញុំ ។ បន្ទាយស្រី មានក្បូរក្បាច់ល្អស្រស់ជាងគេ ។ អូន **កែវ** ក៏ពេញចិត្តហើយឧស្សាហ៍រំលឹក ពីប្រាសាទដ៏ល្អនេះដែរ ។

- បងមើល៍ ! ស្រីៗ ពីដើមមិនអន់ជាងប្រុសៗទេ អ្វីដែលប្រុសៗធ្វើបាន ស្រីៗក៏ធ្វើបានដែរ ។ រូបចម្លាក់ទាំងនេះបញ្ជាក់ច្បាស់ណាស់ ពីវីរភាពស្រីជំនាន់....

ខ្ញុំសម្របតាមអូន **កែវ** :

- កុំថាស្រីពីដើម, ស្រីសម័យវិទ្យាសាស្ត្រក៏នៅតែចិត្តសឿងណាស់ដែរ ។ អូននឹកឃើញទេ ថ្ងៃមុនអូននឹងបងជជែកគ្នាពី "**រឿងចោរភ្នំត្បែង**" អូនថាអ្នកនិពន្ធឈ្មោះ "**ប៊ីវ ឆៃណាង**" បងថាឈ្មោះ "**ហែល ស៊ុផា**" តែបងនៅតែជជែកមិនឈ្នះអូនទៀត. បងក៏សុខចិត្តចាញ់អូនទៅ ! ... តែតាមពិតអ្នកនិពន្ធ "**រឿងចោរភ្នំត្បែង**" នៅតែឈ្មោះ **ហែល ស៊ុផា** អីចឹង !

នាងក្ដិចខ្ញុំយ៉ាងខ្លាំង ។

- បងពូកែរកពាក្យស៊កគេណាស់ ! យូរៗអូនលែងចង់ហ៊ាននិយាយអ្វីតែម្ដង... ខ្លាចបងស៊កឱ្យ !

ខ្ញុំកាន់ស្មានាង ឱនថើបសក់នាងដោយលួងលោមថា :



- បងសុំទោសណា៎ ! ការពិតស្រីៗនៅតែសឿងអីចឹងទោះបីពីដើមក៏ដូចសម័យវិទ្យាសាស្ត្រ .....

នាងក្ដិចខ្ញុំម្ដងទៀត ទាល់តែខ្ញុំស្រែកទើបនាងលែង ។

- បបូរមាត់, ភ្នែកនិងមុខបង ធ្វើឱ្យបងពូកែញញឹមក្នុងការចំអន់ ហើយពូកែរកពាក្យដាក់ផ្លែឱ្យគេ !

ក្រៅពីនេះ នាងតែងរំលឹកខ្ញុំ កុំឱ្យភ្លេច "**ទឹកដីកម្ពុជាក្រោម**" កុំភ្លេចទឹកដី **សុរិន្ទ, ចាន់តាប៊ុន ឆតររាជ** ។ ល ។ កុំឱ្យខ្ញុំស្រវឹងនឹងសេចក្ដីសុខ នៅកម្ពុជាកណ្ដាលឯណោះ ហើយបំភ្លេចការតស៊ូ ។ .... ឱ ! នាងជាវីរកញ្ញាដ៏ឆ្នើមជិតជាប់ដួងចិត្តខ្ញុំ, សម្រាប់ជីវិតខ្ញុំ, និងសម្រាប់អនាគតខ្ញុំ ...... ឱ ! ដឹងជាចិត្តអ្នកឯទៀតយល់ដូចខ្ញុំដែរ ឬយ៉ាងណាទេ ។ ពេលយប់យើងបែកគ្នា យើងតែងលក់ទាំងញញឹមក្នុង សុបិនដ៏ល្អរកអ្វីប្រដូចគ្មាន ។ អូន **កែវ** តែងនាំដំណឹងមកប្រាប់ខ្ញុំជាញឹកញយថា មានអ្នកជិតខាង ឬអ្នកធ្លាប់ស្គាល់នាងជាច្រើន បានមកសម្ដែងនូវការពេញចិត្ត និងសរសើរសំណាងនាង ដែលបានជួបខ្ញុំ.... ទាំងនេះធ្វើឱ្យខ្ញុំខ្លាចខ្លួនឯង រឹតតែខ្លាំងទៅទៀត ។ ធ្លាប់ខិលខូចយូរហើយ, មកធ្វើល្អបានតែបន្តិច ស្រាប់តែមានគេមកលើក

ទឹកចិត្ត.... ឧបមាថា នេះជារឿងរបស់អស់លោកអ្នកអានវិញ តើនឹងនឹកឃើញយ៉ាងណា ? ចាំបាច់ត្រូវខិតខំធ្វើអំពើល្អជាច្រើន ដើម្បីផ្គាប់ចិត្តអូន កែវ ដ៏ល្អរបស់ខ្ញុំ ។ ល្ងាចនេះ យើងអង្គុយជជែកគ្នាយ៉ាងយូរ ទាល់តែអស់រឿងនិយាយ ។ យើងនៅស្ងៀមទាំងពីរនាក់ ។ នាងបើកប៉ុស្តិ៍វិទ្យុដែលមានកម្មវិធីចម្រៀងសម័យទំនើបដ៏ពិរោះៗ។ ខ្ញុំមួល បិទប៉ុស្តិ៍វិទ្យុនោះ ។ នាងបើកខ្ញុំបិទ ។ នាងក្រញៅដៃខ្ញុំ ។

- បទពិរោះៗ សឹងអី, ក្រែងបទហ្នឹងបងចូលចិត្តស្តាប់ណាស់នោះ ?

ខ្ញុំសើចតតបថាម៉េចទេ, តែខ្ញុំបិទវិទ្យុនោះទៀត ។

- បងឯងម៉េចក៏បិទ !

ខ្ញុំសើចទៀត ដែលបញ្ចេញសំឡេងសើចនេះក្នុងបំពង់ក ។ នាងមើលមុខខ្ញុំដោយឆ្ងល់ :

- មើលហ៎ ! បងឯងនេះ.....

នាងទាញវិទ្យុទៅកាន់, តែខ្ញុំទាញយកមកវិញ ។

- ចាំស្តាប់គេច្រៀងធ្វើអី? អូនឯងនិយាយពិរោះជាងគេច្រៀងទៅទៀត.....



នាងអស់សំណើច ។

- បងឯងនេះ .....

- អូនមិនដឹងទេ ថាអូននិយាយពិរោះជាងគេច្រៀងមួយរយមួយពាន់ដងទៅទៀត ។ សំឡេងអូនស្រួយក្រអៅ តើចម្រៀងអ្វីនឹងពិរោះជាងអូននិយាយជាមួយបងនោះ ?

នាងដកដង្ហើមធំ ញញឹមមើលមុខខ្ញុំដោយមេត្រី ។ ខ្ញុំបន្តថា :

- ភ្នែកអូនខ្មៅដូចនីលពេជ្ររតន៍ ។ បងសុំសួរអូន ! តើអូនធ្វើបុណ្យអ្វីពីជាតិមុន បានជាអូនមានសម្រស់លើសគេម្ល៉េះ ?

អូន កែវ មើលមុខខ្ញុំក្នុងក្តីសង្ស័យមិនរំភើប តបថា :

- បងសរសើរអូនពេកហើយ អូនអៀនខ្លួនណាស់ !

- ទេ គឺពិតដូច្នេះមែន ! មើលចុះច្រមុះតូចស្រួចគួរបេតី ចិញ្ចើមកោរថ្មីដូចកៅទណ្ឌ ស្នាអូនរីកត្រគាកសាយចាយភ្នែកអ្នកផង ។ តាមចាស់និយាយថា ត្រគាកសាយអីចឹងងាយកើតកូន... ។

- អូយ ! (នាងក្តិចខ្ញុំ)

- កុំបូរបាច់ច្រើនពេកខ្ញុំអៀនណាស់ ។

- នែ៎អូន ! អ្វីៗ ដែលបងនិយាយសុទ្ធតែជាការពិតទាំងអស់ ។ មើលសុដន់ណែនក្ដន់ ដូចរបស់នាងអប្សរានៅក្លោងទ្វារប្រាសាទអង្គរអីចឹង ! សមពាក់អាវពណ៌ត្របែកព្រៃចេញសាច់សខ្ចីស្ទើរស្រក់ទឹកមាត់ !.......

- បានហើយ ៗ ៗ !

- មិនទាន់បានទេ បើបងមានអណ្ដាតមួយរយ ទើបសរសើរសោភ័ណអូនអស់ ។ សក់អូនខ្មៅរលើបរលង់ដូចស្លាបភូមរា ហើយអង្កាញ់ដូចទឹករលក ......

- ឱ ! លោកកវីអើយ បើពូកែម្ល៉េះៗ មើល៍! រៀបរាប់ឱ្យអស់មកមើល៍ !

- បបូរមាត់ពណ៌ស៊ីជម្ពូ ដូចក្លែបក្រូចបកហើយ គន់មើលម្រាមដៃ (ខ្ញុំថ្ពមដៃនាងមកពិនិត្យ) ដូចដង្ហើមស្រូវប្រកបដោយក្រចករីងស្រួចដូចពណ៌បបូរមាត់ មិនបាច់តុបតែងក៏មានសម្រស់ពីធម្មជាតិដែរ ។

- មានអីទៀត ! (នាងញញឹម លេចខួចលើថ្ពាល់ទាំងគូគួរឱ្យបេតី !



- ចង្កេះ ចង្កានិងជង្គង់ សមឥតខ្ចោះ ។ អូននៅស្ងៀមបន្តិចណា៎ ! ចុះកអូនម៉េចក៏មូលក្ដុលម្ល៉េះ ? ហើយជាងចម្លាក់ណា ដែលបានធ្វើផ្ចិតកអូនបីជាន់ឡើងអង្កាញ់ គួរឱ្យស្រឡាញ់ពេញចិន្ដា !

- បងអើយ ! បង **រ៉ាត** (នាងឧទ្ទាន) នេះពិតជាវាគ្មិនពិតៗ ។

- នៅទៀត ! (ខ្ញុំបន្ត) កំភួនជើងតូចរៀវដូចត្រយូងចេក បើអូនស្លៀកខោរីបបន្តិច ! កំឡោះៗ តាមមើលស្រឡៅភ្នែកអស់ ។

- នែ៎ ! បងសំឡាញ់ ទុកឱ្យអូននិយាយម្ដង! នៅពេលរៀបអាពាហ៍ពិពាហ៍ ចាស់ទុំយើងធ្វើអ្វីក៏សុទ្ធតែនឹកដល់រឿងមង្គល ។ សូម្បីតែការសង់រោង ក៏ត្រូវគិតទិរៈរកទិស ។ មានការទាស់ទែងគ្នាបន្តិចបន្តួច គេតង់នឹកឃើញថ្ងៃរៀបការ ដែលគេសង់រោងផ្កាស្លា នៅក្បែរដើមដូង. នឹកឃើញដើមស្លា ដែលគេកាត់យកមកបាចនៅថ្ងៃមេបាឱ្យពរជ័យ នឹកឃើញកាលគេទាំងពីរ ផ្ទាក់ផ្ទមគ្នានៅរាត្រីដំបូង នៅលើគ្រែ លើកន្ទេលត្រជាក់ដូចព្រំអាទិទេព ហើយគេប្រគំបទ **លោមនាង** យ៉ាងរងំ

កំដរពីខាងក្រៅ... ។ ទាំងនេះហើយជាចំណាងមិនឱ្យគេបែកគ្នា ដែលនេះចងចិត្តគូស្វាមីភរិយាឱ្យចេះស្រឡាញ់ ចេះការពារផ្ទះ ភូមិ ស្រុក នគរទៀតផង... បងឯងយល់ទេ ?

(ខ្ញុំរំភើបនឹងអូន កែវ រកអ្វីប្រៀបពុំបាន)

- កែវ របស់បងអ្វីក៏ល្អម្ល៉េះហ្ន៎ ! អូនធ្វើឱ្យបងស្គាល់និងនឹកឃើញកាន់តែច្រើន អំពីលម្អនៃពូជសាស្ត្រខ្មែរយើង !

- ចាំ ! គឺអូនចេះចាំពីលោកតា ដែលជាគ្រូរបស់ប៉ាអូន ។ បន្តិចទៀត យើងនឹងទៅថ្វាយបង្គំសូមពរពីលោកតានោះហើយ .....

និយាយចប់នាងដកដង្ហើមធំ ។ ខ្ញុំរៀបនឹងសួរនាង. នាងចាប់និយាយមុនថា :

- មានរឿងមួយគួរឱ្យខ្លោចផ្សាណាស់ ដែលអ្នកចាំតៗគ្នាមក គឺកាលសម័យ **ផាបឈួន** មានប្ដីប្រពន្ធមួយគូទើបនឹងការរួច ហើយស្រីជាប្រពន្ធនោះ មានរូបឆោមស្អាតប្រិមប្រិយណាស់ ។ ការរួចទើបបានមួយថ្ងៃ ស្រាប់តែមានឯកអាមាត្យរបស់ "**ផាបឈួន**" មកព័ទ្ធចាប់នាង ដើម្បីយកនាងទៅជូនចៅហ្វាយធំរបស់គេ ។ បងប្រហែលជាជ្រាបហើយថា សម័យ



នោះអំណាច "**ផាបឈួន**" ប៉ុណ្ណា ? នាងកំសត់រត់ពួននៅផ្ទះអ្នកជិតខាង. តែទោះយ៉ាងណាក៏ឥតប្រយោជន៍ដែរ ព្រោះទ័ពគេព័ទ្ធជិតគ្រប់ច្រកក្នុងភូមិទៅហើយ ចាំតែពេលព្រឹកគេនឹងចាប់នាងយកទៅហើយ ។ ដោយអស់សង្ឃឹមនឹងគេចខ្លួន យប់នោះប្ដីប្រពន្ធទាំងគូស្រុះចិត្តគ្នា លោតសម្លាប់ខ្លួនទាំងពីរនាក់ ក្នុងអណ្ដូងទឹក..គឺអណ្ដូងទឹកដែលកាលពីមួយថ្ងៃមុន ជាអណ្ដូងទឹកគេងូតក្រោយពីធីកាត់សក់នោះ ។

យើងដកដង្ហើមធំទាំងពីរនាក់....

- គួរឱ្យខ្លាចណាស់, សម័យមនុស្សជិះជាន់មនុស្ស តែមនុស្សដែលជិះជាន់គេ ដាច់ខាតត្រូវតែមានពៀរវេរា ... បងយល់ដូចអូនទេ ?

ខ្ញុំងក់ក្បាលស្របនឹងនាង រួចថា :

- ប្រាកដហើយ !

- ទៅបង ! អូននឹងនាំបងឱ្យឃើញ ពេលបញ្ចប់ពិធីអាពាហ៍ពិពាហ៍នេះទៀត !

នាងដឹកដៃខ្ញុំឡើងទៅលើផ្ទះ ដែលកំពុងមានបរិយាកាសរីករាយយ៉ាងខ្លាំង....

- បងមើល៍ ! គេទាំងពីរជាប្ដីប្រពន្ធថ្មីថ្មោង កំពុងបត់ជើងទទួលពរសព្ទសាធុការពីញាតិមិត្ត. គេទាំងពីរលើកថាសនុំគម ចេក អន្សមជ្រូក ជូនដល់ញាតិមិត្ត ដែលមករួមក្នុងពិធីរបស់គេនេះ, គេថ្លែងសូមខមាទោស ដល់ញាតិមិត្តទាំងអស់ដែលរវល់ដោយសារតែគេទាំងពីរ ។ គំនរឥវ៉ាន់ខាងលិចនោះជាចំណងដៃ ដល់គូទាំងពីរនេះហើយ ព្រោះអ្នកស្រុកនេះគេកម្រចងដៃជាប្រាក់កាសណាស់, គឺគេចងជារបស់ ដែលអាចឱ្យសាមីខ្លួនអ្នកការ អាចមើលឃើញរហូតដល់ចាស់ស្លាប់ .....

- ខុសប្លែកពីអ្នកក្រុង ដែលពេលការម្ដងៗ... គ្នាអ្នកភ្ញៀវខ្វល់ខ្វាយតែពីរឿងខ្វះប្រាក់ចងដៃ ...... (ខ្ញុំបន្ថែម)

កែវបន្តថា :

- បងឃើញទេ ? មេបាចាស់ទុំទាំងខាងស្រីទាំងខាងប្រុស ញញឹមពេញចិត្តនឹងកូនរបស់ខ្លួន ... ។ គឺព្រោះតែយ៉ាងនេះហើយ ទើបនៅស្រុកនេះ គេកម្រឃើញប្ដីប្រពន្ធណាលះលែងគ្នាណាស់ ។ បងមើហ៍ ! កំឡោះក្រមុំជាមិត្តភក្ដិសាមីខ្លួនការ ក៏រីករាយដែរ .... គេញញឹមទុកថា ថ្ងៃខាងមុខនេះគេនឹងជួបប្រទះពេលល្អបែបនេះហើយ .......



ការបញ្ចប់ពិធីនេះវែងណាស់ ព្រោះតែក្មេង ៗ ជំទង់. កំឡោះក្រមុំ ជាមិត្តភក្ដិសាមីខ្លួនអ្នកការ ចំអន់លេងជាមួយគូស្វាមីភរិយាថ្មី ដោយឱ្យប្ដីក្បៀកកប្រពន្ធ, ឱ្យប្រពន្ធថើបប្ដី, ប្រពន្ធបុចស្លាជូនប្ដីជាដើម បង្កើតជាបរិយាកាសអ៊ូអរយ៉ាងខ្លាំង ។

ដោយចង្កៀតពេក, អូន **កែវ** ទាញដៃខ្ញុំចេញមក .....

នាងនិយាយថា :

- នេះជាអនុស្សាវរីយ៍ចុងក្រោយ ក្នុងការដែលមិត្តភក្ដិខ្លួន ធ្វើដំណើរទៅសាងជីវិតមួយថ្មីហើយ ។ ស្អែកឬខានស្អែកគេនឹងបែកគ្នា ព្រោះខ្លះចេញទៅណេះ ខ្លះចេញទៅណោះរកស៊ីឯបឹងគ្រប់ៗគ្នា.... ។ អីចឹងហើយបានជាអ្នកស្រុកនេះ គេចូលចិត្តរៀបការកូននៅខែអស្សុជ ដែលទើបតែរាំងភ្លៀង. ដល់រៀបការរួច ប្ដីប្រពន្ធនឹងមានរបរផ្ដើមជីវភាពជាស្រេច ។

**កែវ** នាំខ្ញុំទៅភូមិខាងក្រោយទីស្នាក់ហើយចង្អុលប្រាប់ខ្ញុំនូវកន្លែងដែលជីតានាងធ្លាប់ចងអង្រឹង ឱ្យនាងយោលលេងកាលពីនៅតូចៗ ហើយភូមិនេះឥឡូវ ជីតានាងចែកឱ្យឪពុកម្តាយនាងទៅហើយ ។ សំឡេងហោកព្រៀវនៅតែរសាត់ពីផ្ទះធំមក

- អស្ចារ្យណាស់ ! បងមិនដែលឃើញដូច្នេះទេ !

នាងញញឹម ។

- ឪពុកអូនបានខ្សិបប្រាប់អូនថា គាត់នឹងរៀបការអូន និងបងនៅទីនេះដែរ ឱ្យអឺកធឹកជាងនេះ. ព្រោះគាត់ស្រឡាញ់អូនណាស់ ....តែ ... តែ .....

ស្រាប់តែនាងយំខ្សឹកខ្សួល ....ខ្ញុំស្រឡាំងកាំង ....

- ម៉េចក៏អូនយំ ?

នាងយំរឹតតែខ្លាំង. ចិត្តខ្ញុំកាន់តែរំជួល ។

- មានរឿងអី ? ប្រាប់បងមក កែវ អូន ! ឬមួយអូនមិនទុកចិត្តបង ? អូនខ្លាចបងមិនស្មោះនឹងអូនឬ ? ព្រះអើយបងស្រឡាញ់អូននេះ គ្មានចន្លោះចិត្តត្រង់ណាទេ !

នាងគ្រវីក្បាល តែទឹកភ្នែកនាងហូររហាម ហើយផ្អែកក្បាលលើទ្រូងខ្ញុំ ។ ខ្ញុំជូតទឹកភ្នែកឱ្យនាង រួចដៃម្ខាងដឹកដៃនាង និងដៃម្ខាងទៀតក្រពាត់ពីក្រោយខ្នងនាង លួងនាង ។

- កុំយំអីអូន ! បើអូនឃើញបងខុសចន្លោះត្រង់ណាអូនប្រាប់បងមកចុះ បងនឹងកែខ្លួនតម្រូវចិត្តអូន !

នាងនៅតែគ្រវីក្បាល រួចនាងនិយាយក្បែរទ្រូងខ្ញុំថា :



- យើងជាកូនកំព្រា... កំព្រា... ដូចគ្នា... ។ ដល់ថ្ងៃយើងរៀបការ...យើងឥតមានឪពុកម្តាយ...ញញឹមមើលដោយពេញចិត្តមកយើងទេ....

សម្តីនាងនាំមកនូវក្តីរន្ធត់ចិត្តជាខ្លាំងដល់ខ្ញុំ ។ ខ្ញុំអួលដើមកដែរ រួចស្រក់ទឹកភ្នែកជាមួយនាង ។ ខ្ញុំនិយាយកម្លាចិត្តនាង :

- ឈប់យំទៅអូន ! អ្នកមានគុណរបស់យើងមិនបានមកអបអរនៅពេលរៀបអាពាហ៍ពិពាហ៍យើងមែន. តែព្រលឹងលោកបានសុខមនោរម្យហើយ ព្រោះឃើញយើងស្រឡាញ់គ្នាដោយស្មោះស្ម័គ្រ ។ លោកញញឹមដោយឃើញអូនធ្វើអំពើល្អច្រើនចំពោះលោក. លោកពេញចិត្តនឹងចរិយាអូន ដែលថ្លៃថ្នូរជាកំពូលនារី..... អារម្មណ៍លោកបានស្ងប់ហើយ ព្រោះអូនជាអ្នកស្នងអំពើល្អរបស់លោក....

កែវ ស្តាប់សម្តីខ្ញុំបាន ។ នាងឈប់យំ ។ នាងសម្លឹងខ្ញុំហាក់ចង់ចារផ្ទុះនូវគំនិតខ្ញុំ រួចភ្នែកនាងប៉ប្រិចយ៉ាងញាប់ ។

នៅថ្ងៃត្រង់នោះ យើងយកចង្ហាន់ទៅប្រគេនព្រះសង្ឃទៅប្រគេនលោកតាងវត្ត ។ លោកចៅអធិការនេះឯងជាគ្រូ

ឧបជ្ឈាយ៍របស់ប៉ាអូន **កែវ** ។ លោកបានឱ្យពរយើងយ៉ាងវែងឱ្យយើងបានសុខ មានសុភមង្គល មានកូនមានចៅមួយឆ្នាំមួយៗ ។ លោកតាបានចងដៃយើងនូវចិញ្ចៀនកេរបុរមបុរាណមួយ ហើយលោកមានពុទ្ធដិកាថា នឹងនិមន្តមកផ្ទាល់ព្រះអង្គនៅពេលយើងរៀបការក្នុងខែពិសាខខាងមុខនេះ ។

ថ្ងៃរសៀលយើងលាលោកតាត្រឡប់មកភូមិថ្កុលវិញ។ ខែអស្សុជជាចុងរដូវភ្លៀងទៅហើយ.. ថ្ងៃរសៀលព្រះអាទិត្យចាំងយ៉ាងខ្លាំង ។ អូនកែវដើរមុខ. ខ្ញុំដើរក្រោយតាមផ្លូវជើងដែលកាច់ចុះកាច់ឡើង ដូចដានពស់កាត់វាលត្រែង ។ មុខអូន **កែវ** ឡើងក្រហមដោយកំដៅថ្ងៃ តែមុខនេះនៅតែញញឹមជានិច្ច ។ ខ្ញុំមើលទៅ នាងបែបហត់ណាស់ហើយ ក្នុងការដើរកណ្ដាលថ្ងៃក្ដៅដូច្នេះ ។

- អូនប្រហែលជាហត់ណាស់ហើយ ព្រោះអូនមិនធ្លាប់ធ្វើដំណើរហាលថ្ងៃក្ដៅយ៉ាងនេះ ។ បងឯណេះ មានកម្លាំងគ្រប់គ្រាន់ បងអាចអៀវអូនបានទៀតផង ។ ឥឡូវបងអៀវអូន ឡើងមក !.......

- ទេ ! បងឯងក៏ហត់ដែរ !



ទោះបីជានាងព្រមឬមិនព្រមក៏ដោយ ខ្ញុំស្ទុះទៅចាប់បីត្រកងនាង ហើយដើរយ៉ាងលឿន ..... ។

- ដាក់អូនចុះវិញទៅ !

ខ្ញុំពុំព្រមដាក់នាងចុះវិញទេ. តែដើរបានប្រហែលជាហាសិបម៉ែត្រខ្ញុំក៏ហត់ដែរ ឈានជើងទៅមុខមិនចង់រួច ។

- ឃើញទេ? នាំឱ្យតែបងហត់អត់ប្រយោជន៍ ។ ឥឡូវដាក់អូនចុះវិញ យើងកៀកដៃគ្នាដើរបន្តិចៗទៅមិនយូរប៉ុន្មានទេ យើងនឹងដល់ភូមិហើយ ... ខ្ញុំក៏ព្រមដាក់នាងចុះ ។ អូន **កែវ** បានកំណាត់ឫស្សីមួយជាឈើច្រត់ ដៃម្ខាងច្រត់លើកំណាត់ឫស្សី ដៃម្ខាងទៀតតោងស្មាខ្ញុំ ....... យើងបន្តដំណើរទៅមុខទៀត ។

- យីក្ដៅអីម្ល៉េះហ្ន៎ ! វាលនេះរកតែដើមឈើមួយដើមជ្រកក៏ពុំបានផង ។ នៅទីដាច់ស្រយាលពីភូមិនេះ សុទ្ធតែវាលល្វឹងល្វើយ ស្ងប់ខ្យល់ហើយស្ងាត់ឈឹង សូម្បីតែសម្លេងចាបឬសារិកាកែវមួយក៏គ្មានឮដែរ ។

ដើរបណ្ដើរ ខ្ញុំស្រែកលុះត្រាតែភ្លាត់សម្លេងថា :

- លោកអើយ មកជួយអូន **កែវ** ផង ! អូន **កែវ** មិន

ដែលប្រព្រឹត្តអំពើបាបអ្វីសោះទេ ។ អូន កែវ ជាទេពធីតាចុះពីស្ថានលើមកសង្គ្រោះមនុស្សលោក... ឥឡូវអូន កែវ ដើរកាត់វាលអស់កម្លាំងរវើរវាយទៅហើយ....

កែវ ទះមាត់ខ្ញុំថ្នម១..... នាងញញឹម !

- បងឯងនេះ !

- គឺអូនឯងជាទេពធីតាមែននោះអី? ព្រះអង្គនៅឋានលើ មិនគួរពុំបើកចក្ខុមើលមកអូនឯណេះសោះ !

- បងចាំខឹងនឹងព្រះអាទិត្យធ្វើអ្វី? ទោះក្តៅយ៉ាងណាក៏ដោយ ឱ្យតែអូនបានដើរជិតបងអូនសប្បាយពេកណាស់ទៅហើយ !

- ហាំ ! ហាំ ! អូនឯងនេះចំជាគួរឱ្យស្អប់មែន !

- មិនដឹងជាកម្លាំងអ្វី មកធ្វើឱ្យអូនលែងខ្លាចរអា ពីរឿងកំដៅថ្ងៃនេះទៅវិញ !

យើងកៀកដៃគ្នាដើរយ៉ាងអង់អាច ប្រកបដោយទឹកមុខញញឹម ។

ស្រាប់តែអូន កែវ ឈប់ស្ងៀម ហើយចង្អុលប្រាប់ខ្ញុំ :

- បងមើល៍ ? មេឃស្រទំនៅម្ខាងឯណោះ ហើយកាន់



តែដេញជិតមកដល់ហើយ ! បងឯងឃើញទេ ? នុំះ ហ្ន៎ ខ្សែខ្មៅហាក់ដូចជាគេចងកាត់សន្ធឹងវាលត្រែង !

ខ្សែខ្មៅនោះក៏មកដល់យើងទាំងពីរ ហើយមេឃស្រទំភ្លាមដែរ ។

- អូនឃើញទេ ? បងស្រែកអម្បាញមិញក្តៅក្រហាយដល់ទេវតាភ្លាមដែរ ! អូនឯងនេះចំជាមានបារមីមែន !

នាងសើចហើយគក់ខ្ញុំ...

- បងឯងនេះចេះតែថាហើយ ! បងភ្លេចហើយឬអីថាកាលណាមេឃក្តៅខ្លាំង មិនយូរប៉ុន្មានច្បាស់ជាមានភ្លៀងធ្លាក់មិនខាន ។ នុំះ ហ្ន៎ ! ពពកដុំៗរសាត់មកហើយ !

- ទេ ! ពិតជាបុណ្យបារមីរបស់អូនឯងហ្នឹង ! អូនជាបុត្រីព្រះឥន្ទ្រាធិរាជ តើព្រះអង្គឯណា ក៏ដាច់ចិត្តឱ្យបុត្រីសំណប់ដើរហាលថ្ងៃអីចឹង ?

នាងកៀកចង្កេះខ្ញុំ. ដៃនាងម្ខាងទៀត ទាញដៃឆ្វេងខ្ញុំឱ្យកៀកកនាង ។ យើងដើរមួយ ៗ បោះជើងត្រូវគ្នាដូចហាត់ទាហាន ។ ក្បាលនាងផ្អែកលើស្មាខ្ញុំ ។ នាងនិយាយថា :

- អូននិយាយមិនពីរោះដូចបងសោះ ! អូនដឹងយ៉ាង

ច្បាស់ថា បងស្រឡាញ់អូនដោយស្មោះត្រង់. អូនសប្បាយចិត្តណាស់ ហើយអូនតែងគិតថា នេះប្រហែលមកពីព្រេងវាសនារបស់អូនទេ ។ ចៃដន្យអ្វីម្ល៉េះ ដែលនាំឱ្យយើងស្គាល់គ្នា ហើយនាំចិត្តយើងឱ្យក្លួចធ្លាក់រកគ្នាភ្លាម ....

- មែន ! នោះជាវាសនាបងសម្បើមដែរ. បើបងយឺតពេលតែបន្តិច នាំឱ្យខកខានពុំបានស្គាល់អូន ហើយអូនបានទៅគេ. ប៉ុណ្ណេះបងមិនដឹងជាស្ដាយអូនយ៉ាងណាទេ ! រាត្រីដំបូងដែលបងបានឃើញស្រមោលអូន...... កាយវិការអូនធ្វើឱ្យបងចាប់ចិត្តណាស់. បងបានលួចស្រឡាញ់អូនភ្លាម ហើយពេលដែលយាយ ម៉ែន និយាយពីអំពើល្អរបស់អូនប្រាប់បង.. បងក៏ស្រឡាញ់អូនដោយគ្មានសំចៃ !

នាងសើចតិចៗ យ៉ាងត្រជាក់អារម្មណ៍ :

- បងឯងគួរឱ្យស្រឡាញ់អីម្ល៉េះទេ ?

ខ្យល់បក់មកដល់ហើយ ។ វាលស្រែងទាំងមូល កំពុងមានចលនាដូចទឹករលក ។ អូន កែវ និយាយទៀតថា :

- ភ្លៀងធំ មុខជាមកស្ទាក់យើងកណ្ដាលផ្លូវហើយ ! ទម្រាំដល់ភូមិវិញ យើងទទឹកជោគខ្លួនជាស្រេច! នេះប្រហែល



ជាភ្លៀងចុងរដូវ ដែលចាស់ៗតែងតែហៅថា ភ្លៀងផ្ដាំក្ដាមផ្ដាំខ្យងនោះហើយ....

- ប្រសើរណាស់ ! យើងនឹងដើរកាត់ភ្លៀងនេះម្ដងឱ្យសប្បាយ ព្រោះព្រះឥន្ទ្រតម្រូវឱ្យភ្លៀង ចំពេលដែលយើងកំពុងដើរកាត់វាលតែពីរនាក់...

ភ្លៀងចាប់ស្រក់មកតក់ៗ ។ ពពកខ្មៅរសាត់កាន់តែលឿន ។ ផ្គរលាន់គ្រហឹមមកពីនាយ... ហើយខ្យល់ក៏កាន់តែបក់បោកមក ធ្វើឱ្យសក់អូន កែវ រសាត់រសាយ ។ មេឃចាប់ងងឹត. នៅភូមិខាងមុខយើង ដែលមុននេះបន្តិច យើងអាចឃើញដើមឈើយ៉ាងច្បាស់ ឥឡូវស្បៃសនៃទឹកភ្លៀង សន្ទឹងគ្របបាត់អស់ទៅហើយ ។

មិនយូរប៉ុន្មានខ្យល់បក់យ៉ាងខ្លាំងក្រឡាប់ចាក់ទឹង នាំមកជាមួយនូវដំណក់ទឹកកាន់តែធំៗ ធ្លាក់លើក្បាលឈឺគ្រាន់បើតែយើងទាំងពីរ ឥតភ័យព្រួយអ្វីសោះទេ ។ យើងទទឹកជោគរៀងៗខ្លួន តែយើងឥតដឹងថារងាសោះឡើយ ។ កែវ ក៏ដូចខ្ញុំយើងរីករាយ នឹងដើរកាត់វាលល្ហល្ហេវ កណ្ដាលព្យុះធំតែពីរនាក់ ។ សត្វកង្កែប ក្ដុកក្ដាត់យំឆ្លើយឆ្លងគ្នារងំបីដូចតន្ត្រីវង់ធំ

ប្រគំបទពិរោះចាប់ចិត្តកណ្ដាលវាលស្រែង ។ សត្វទាំងនេះប្រគំភ្លេងជូនដំណើរយើងដែរ ។

- យើងត្រូវចំណាំផ្លូវជើងតូចនេះ ...(កែវនិយាយមកកាន់ខ្ញុំ) ។ បងមើល៍ ! បើសសំព្រុះគ្រប់ជ្រុងយ៉ាងនេះ យើងមិនអាចដឹងថា ភូមិយើងនៅទិសណាទេ ! ។

យើងមកដល់កូនប្រឡាយមួយតូច ។ កាលមិនទាន់ភ្លៀង. ប្រឡាយនេះគ្មានទឹកមួយដំណក់ទេ លុះភ្លៀងធ្លាក់ខ្លាំងដូច្នេះ ទើបមានទឹកហូររឹម១ យើងត្រូវឆ្លងកាត់ប្រឡាយនេះ ដែលមាត់ច្រាំងជំរាលទៅនោះគឺជាដីកណ្ដៀងរអិលសំបើមណាស់ ។ អូន កែវ ឈានចុះច្រាំងទាំងញញើតញញើម ព្រោះមុននេះបន្តិច នាងភ្លាត់ជើងរអិល បើកុំតែខ្ញុំទប់ទាន់កុំអីដួលបាត់ទៅហើយ ។ ខ្ញុំលើកបីនាងដើរលប១ឆ្លងកូនប្រឡាយ :

- កុំខ្លាច ... ! ពេលណាបងនៅជាមួយអូន បងមានកម្លាំងលើសដើម ហើយអាចពអូនរហូតដល់ភូមិជាដើម !

យើងរើសបានភ្នួលកណ្ដាច់មួយដែល ប្រហែលជាអ្នកចងសន្ទូចបោះចោលក៏មិនដឹង ។ ភ្នួលនេះយើងរើសយកមកទទូរ. យើងនៅពីក្រោមភ្នួលតែមួយនេះ ដែលអាចឱ្យយើង



ការពារមិនឱ្យគ្រាប់ភ្លៀងធ្លាក់លើបាន ។ ខ្យល់និងកម្លាំងទឹកភ្លៀងចេះតែបំប៉ើងភ្នួលយើង. តែយើងខំទប់ ខំកាន់ខាងចុង. បីដូចប្ដីប្រពន្ធកំពុងទល់ កំពុងជ្រែកការពារ ខ្ទមតូចរបស់ខ្លួនមិនឱ្យប៉ើងតាមកម្លាំងខ្យល់ព្យុះបាន ។

មកដល់ភូមិ ផ្ទះឪពុកមាអូន កែវ... ឪពុកមាអូន កែវកំពុងរកអ្នកស្រុកបួនប្រាំនាក់ទៅតាមយើង ដោយខ្លាចយើងវង្វេងផ្លូវ ។ ស្អែកឡើង អ្នកស្រុកបបួលយើងទៅលេងកឋិនឯ "វត្តលើទឹក" ទៀត ។ អូន កែវ បានប្រាប់ខ្ញុំថា បានជាគេហៅ "វត្តលើទឹក" ដូច្នេះ ព្រោះវត្តនេះនៅកណ្ដាលបឹងទន្លេសាប ខែប្រាំងក៏ដូចខែវស្សា មិនដែលឃើញទឹកគោកនៅទីវត្តនោះម្ដងណាទេ ។ ពីភូមិទៅវត្ត បើនៅខែប្រាំងដីរាំងស្ងួត គេច្រើនធ្វើដំណើរតាមរទេះ ទាល់តែដល់មាត់បឹងទន្លេសាប ទើបគេឆ្លងទូកទៅ តែរយៈពេលមួយបារីក៏អាចទៅដល់ស្រេច ។ តែដោយខែនេះ ដីនៅតែសើមប៉ាច់នៅឡើយ គេច្រើនធ្វើដំណើរតាមទូកកាត់កូនព្រៃកមួយ ដែលជាដៃស្ទឹងពីសៀមរាបមក ។ ព្រះគ្រូចៅអធិការ "វត្តលើទឹក" ក៏ជាគ្រូឧបជ្ឈាយ៍ របស់ប៉ាអូន កែវ ទៀត..... លោកអួតសរសើរពីលក្ខណៈ សម្បត្តិប៉ាអូន កែវ

ជាច្រើន ។ អស្ចារ្យណាស់ !.....ប៉ាអូន កែវ មានកេរ្តិ៍ឈ្មោះល្អល្បីរន្ទឺគួរឱ្យគោរព។ លោកគ្រូចៅអធិការល្បីល្បាញខាងសាក់បញ្ចុះមន្តអាគមលើសាច់មនុស្សទៀតផង ។ ដូច្នេះហើយទើបឆ្លៀតពេលទំនេរដែលអូន កែវ សម្រាកថ្ងៃ ខ្ញុំលបទៅថ្វាយបង្គំលោក សុំសាក់រូបផ្កាចំប៉ាមួយទង នៅលើដើមទ្រូងឆ្វេងខាងឆ្វេង ដោយឥតឱ្យអូន កែវ ដឹង ។ ថ្ងៃរសៀលត្រជាក់ក្រោយពីវេរអង្គកឋិនរួចហើយ យើងក៏ធ្វើដំណើរត្រឡប់មកភូមិវិញ តាមទូកសំប៉ានមួយយ៉ាងធំមានដំបូលផង ។ ទូកសំប៉ានមានដាក់ម៉ាស៊ីនកាណូតផង ដោយពុំបាច់រវល់ចូកចែវឡើយ ព្រោះទោះបីចែវក៏ចែវពុំរួចដែរ ដោយហេតុថាទឹកអូរនោះហូរខ្លាំងពេក ។ ការធ្វើដំណើរត្រឡប់មកវិញនេះគឺច្រាសទឹកផង ។ សំប៉ានមួយនេះ ផ្ទុកមនុស្សបានច្រើនណាស់ សឹងអស់មនុស្សដែលទៅលេងកឋិន ។ មេឃស្រទុំ, អូន កែវ និងខ្ញុំឡើងទៅអង្គុយលេងលើដំបូលសំប៉ាន ។

សំប៉ាននេះចេះតែបន្តដំណើរតិចៗឆ្ពោះទៅមុខ ល្បឿនវាមិនលឿនទេ ។ ម៉ាស៊ីនបង្វិលស្លាបចក្រជំរុញទៅមុខ ប៉ុន្តែខ្សែទឹកចេះតែទាញថយក្រោយ ។ ក៏ប៉ុន្តែការធ្វើដំណើរយឺតៗ



យ៉ាងនេះជាការល្អប្រសើរណាស់ សម្រាប់អូន កែវ និងខ្ញុំ បានទស្សនាទេសភាពទាំងឡាយស្រស់ញញឹម ដែលនៅរៀងអាយតាមដងអូរ ។

ផ្កាត្របែកព្រៃចោលពណ៌ស្រស់, ផ្កាត្រកួនរាយពណ៌ល្អឥតខ្ចោះនៅតាមមាត់ច្រាំង, ផ្កាត្រែងយោលរេរានិងផ្កាមួយរយមុខទៀត រៀបរចនាស្រស់ល្អដូចក្បាច់អង្គរវត្ត ។ តើទេសភាពល្អប្រណីតនេះ រៀបឡើងសម្រាប់ទទួលនរណា?

- ទីនេះគួរឱ្យសប្បាយណាស់ ! (កែវចង្អុល) មានផ្កាគ្រប់ពណ៌រីកស្គុសស្គាយ ។ បងចូលចិត្តទេសភាពបែបនេះទេ ?

- ទេអូន ! អូនស្រស់ជាងបុប្ផានេះទៅទៀត ! អូនឃើញទេ ? បុប្ផាទាំងនេះកំពុងច្រណែននឹងអូន ដោយសារចាញ់សម្រស់អូន !

នាងនៅស្ងៀមតែនាងញញឹម ។ ខ្ញុំទាញស្មានាងមកកៀកនឹងខ្ញុំ ហើយខ្សឹបក្បែរត្រចៀកថា :

- គ្មានអ្វីដែលស្រស់ជាងអូនទេនៅក្នុងលោកនេះ នុ៎ះ! សារិកាកែវកំពុងប្រចឹកគ្នាលេងលើមែកត្រសេក, វាទាំងពីរជាសង្សារនឹងគ្នា ដូចអូននឹងបងដែរ អាឈ្មោលច្រណែននឹងបង

ដោយសង្ស្ការបងស្រស់ជាងសង្សារវា ។ សត្វលលក សត្វពពួល ពពេច... បក្សីទាំងអស់នៅតាមអូរនេះលែងហ៊ានច្រៀង លែងហ៊ានបួលគ្នាទៀតហើយ. វាខ្លាសអូនដោយសម្លេងវា ពីរោះចាញ់សម្លេងអូនឆ្ងាយណាស់ ។ អូនមើល៍ ! ផ្កាវាមិនហ៊ានរីកទៀតទេ ទោះបីវាធ្លាប់រីកស្រស់បំព្រង តាមការកំណត់របស់វាក៏ដោយ ។

ទឹកហូរតួចខ្លាំង គ្រឿងចក្រក៏បង្កើនល្បឿនខ្លាំងជម្នះចលនាទឹក ។ ទូកលូនទៅមុខសន្សឹម១ ។ ចលនាទឹកនិងទូកប្រៀបដូចជាផ្លូវជីវិតយើងដូច្នេះដែរ ។ ក្រោយយើងរៀបការហើយ យើងប្រយុទ្ធតស៊ូដើម្បីជីវិតរុងរឿង ។ បងនិងអូនជាម៉ាស៊ីនទូក ដែលខំជម្នះគ្រប់ឧបសគ្គ ត្រូវព្យាយាមដូចទូកខំជម្នះចលនាទឹក ...... ។

- អូនសូមជូនយោបល់មួយ ! ជីវិតជាបញ្ញតិមួយមិនទៀងទាត់ ។ វាកំណត់ទៅតាមវាសនា ។ បើវាសនាមានក៏មាន ក៏រុងរឿងមិនបាច់ខំប៉ុន្មាន ។ ព្រហ្មលិខិតទេដែល....

ទើបនិយាយបានប៉ុណ្ណេះខ្ញុំនិយាយកាត់ :

- អូនអើយ ! បើយើងដេកចាំតែវាសនា គិតរង់ចាំតែ



ព្រហ្មលិខិត យើងនឹងធ្លាក់ខ្លួនក្រ អត់បាយកូនស្លាប់ហើយ !

- យី! និយាយអីវែងឆ្ងាយម្ល៉េះ!

- ពិតហើយ ការកសាងជីវិតទៅអនាគត ត្រូវគិតឱ្យល្អិត និងម៉ត់ចត់ ។

- ណ្ហើយ ! យើងជាអនាគតស្វាមីភរិយាត្រូវរួមទាំងផ្លូវកាយផ្លូវចិត្ត មតិយោបល់ ហើយយកទៅអនុវត្តឱ្យចេញផ្លែផ្កា ។ អូនជឿលើព្រេងវាសនា ឯបងលើការតស៊ូ-ព្យាយាម-ការសន្សំសំចៃ ...... សុទ្ធតែត្រូវមួយផ្នែកម្នាក់ ។

ប៉ុន្តែ ដើម្បីឱ្យជីវិតរុងរឿងរស់រវើក និងជឿនលឿនយើងត្រូវយកមតិទាំងពីរមកអនុវត្ត ។ ការតស៊ូព្យាយាម សន្សំសំចៃជាករណីចាំរួមផ្សំនឹងវាសនាកំណត់ឱ្យផង យើងក្លាយទៅជាអ្នក.... ។

- អស្ចារ្យមែនសង្ឃឹមមួយរយភាគមួយរយ... ។

# ៥

# ស្នេហ៍ត្រូវការអ្វីខ្លះ?

អូនកែវ ចូលរៀនថ្នាក់ទី ១ ទំនើបជាតិនៅបវេសនកាលឆ្នាំ ១៩៦៩ នេះ....

នាងជាសិស្សឆ្លាតហើយមានចិត្តល្អប្រពៃ ចំពោះសិស្សជាមិត្តរួមថ្នាក់ និងជាទីស្រឡាញ់នៃគ្រូបាធ្យាយ ។ ឈ្មោះនាងនៅក្នុងសាលា គឺ "ចំប៉ាកែវ" ។ ឯនៅផ្ទះ គឺគេហៅកាត់យកកន្ទុយឈ្មោះនាងប៉ុណ្ណោះ ។

ខ្ញុំបានបង្ហាត់នាងបន្ថែមនូវមុខវិជ្ជាសំខាន់ៗ ហើយនាងធ្វើបាយដោយផ្ទាល់ដៃ លើកមកឱ្យខ្ញុំរាល់ពេលនៅផ្ទះ ជូនមែនទីដែលខ្ញុំសំណាក់ ។ នាងជាសិស្សខ្ញុំផង, ជាសង្សារផង, ជាសហការីផង ព្រោះពេលទំនេរ នាងបានជួយចម្លងអត្ថបទខ្ញុំ, ពិសេសទៅទៀត នាងជាលេខាធិការផ្ទាល់របស់ខ្ញុំតែម្តងព្រោះសំបុត្រស្នាមដែលមិត្តភក្តិនៅភ្នំពេញផ្ញើមកខ្ញុំ គឺតាមអាស័យ-



ដ្ឋានផ្ទះរបស់នាង ។ ខ្ញុំបានឱ្យសិទ្ធិនាងអានសំបុត្រទាំងនោះ ហើយសំបុត្រណាដែលត្រូវតប នាងតែងធ្វើសេចក្តីព្រាងមកឱ្យខ្ញុំពិនិត្យ ។

សំបុត្រមិត្តភក្តិសឹងតែទាំងអស់នោះ ផ្ញើមកសំដែងសេចក្តីត្រេកអរដល់ខ្ញុំដែលបានជួប កែវ តូចផ្ញើមចំណាប់ព្រោះខ្ញុំបានផ្ញើដំណឹងទៅពួកគេ, អួតប្រាប់គេពីសម្រស់ កែវ ពីអ្វីៗដែលនាំឱ្យចិត្តខ្ញុំ បានសុខមនោរម្យ នៅលើទឹកដីសៀមរាបអង្គរនេះ ។

ការសិក្សារបស់ កែវ, ការស្រាវជ្រាវរបស់ខ្ញុំ សេចក្តីសុខមនោរម្យក្នុងចិត្តរបស់ខ្ញុំ កំពុងបោះជំហានព្រមៗគ្នាយ៉ាងអង់អាច ពោរពេញទៅដោយក្តីសង្ឃឹម ។ ជីវិតខ្ញុំរស់មកជាងម្ភៃឆ្នាំ ហាក់ដូចជាសាប ប្រហាតគ្មានរសជាតិអ្វីបន្តិចសោះហើយ ទើបនឹងមកមានន័យនៅពេលប៉ុន្មានខែនេះឯង ។ ខ្ញុំគិតថា ខ្លួនខ្ញុំនេះជាមនុស្សមានសំណាងខ្ពស់ជាងគេបង្អស់ ។

មិនចំពោះថាខ្លួនខ្ញុំឬមនុស្សដទៃទេ ដែលចង់នៅជិតកែវ, សូម្បីតែសត្វតិរច្ឆាន ក៏ស្រលាញ់ចង់រស់នៅជិតអូន កែវដែរ ។ សត្វព្រាបដែលមិនដឹងមកពីខ្លះ បានមកនៅយ៉ាងសុខ

សាន្ត...នៅចំហៀងគេហដ្ឋានរបស់នាងនាធ្លាខាងលិច អូន កែវ បានឱ្យគេធ្វើជាលំនៅសត្វព្រាប ហើយមានសត្វព្រាបរាប់រយកើតកូនពូនជាចៅរីតតែច្រើនឡើងៗ។ រាល់ពេលល្ងាចត្រជាក់ សត្វព្រាបទាំងនោះ មករង់ចាំកកស្រទាប់លើទីធ្លាមុខផ្ទះ. លើដំបូលផ្ទះ. លើរបងផ្ទះ... ព្រោះរាល់ពេលល្ងាច អូន កែវ តែងកាន់ល្អីស្រូវស្ងោរ យកមកបាចឱ្យពួកវាស៊ី ។ ពួកសត្វព្រាបទាំងនេះ ហាក់ដូចជាពលរេហ៍ដែលមកចាំទទួលព្រះនាងខត្តិយានីម្ចាស់ស្រីរបស់វា ។ វាស្រឡាញ់ម្ចាស់ស្រីវាណាស់ ពេលម្ចាស់ស្រីវាចេញមក វាហើរទៅទំលើស្មាម្ចាស់ស្រីវា វាយកចំពុះទៅច្រូតសក់ម្ចាស់ស្រីវា វាយកក្បាលទៅត្រដុសនឹងថ្ពាល់ម្ចាស់ស្រីវា ហាក់ដូចជាខ្សិបប្រាប់ម្ចាស់ស្រីវាថា នឹងមិនទៅណាឆ្ងាយពីម្ចាស់ស្រីដ៏ស្អាតរបស់វានេះទេ ។ អូន កែវ ញញឹមប្រឡែងជាមួយសត្វព្រាប ហាក់ដូចជាម្ដាយមានព្រហ្មវិហារ-ធម៌ទៅលើកូន ។ ពុំមែនមានតែសត្វព្រាបទេ គឺមានសត្វក្ងោកញីឈ្មោលទៀតផង ដែលនាងបានចិញ្ចឹមតាំងពីតូច ៗ ដល់ធំឡើង ក្ងោកនេះក៏មិនទៅណាចាកចោលម្ចាស់វាដែរ ។ ក្ងោកទាំងគូនេះតែងហើរទៅទីផ្សារនិងទីដទៃៗទៀត ដែលហើរទៅ



ដល់ទីត្រង់ណាហើយ មានគេបាចចំណីឱ្យវាស៊ីទៀត ហើយគេឱ្យក្ងោកទាំងគូនេះ គំនាប់ពង់បង្ហាញរាង ព្រោះសត្វនេះចេះស្ដាប់ហើយធ្វើតាមពាក្យមនុស្ស ។ សូម្បីតែសត្វរបស់អូន កែវ ក៏គេចូលចិត្តដែរ ។ សត្វពពែ. មានញីមានឈ្មោល មានកូនតូចធំ ក៏រស់នៅយ៉ាងក្សេមក្សាន្តជាមួយអូន កែវ ដែរ ។ ពពែតូចតែងរត់មករកនាង ដោយបញ្ចេញសូរស័ព្ទថាមែ ! មែ ! នៅពេលដែលពពែធំធ្វើបាបវា ។ វាហាក់ដូចជាចង់រត់មកឱ្យម្ដាយជួយវា ហាក់ដូចជាហៅអូន កែវ ថា ម៉ែ ! ម៉ែ ! ។ អូន កែវ ឆុងទឹកដោះគោឱ្យពពែតូចបៅ យកបាយដាក់លើបាតដៃនាងឱ្យពពែតូចអាស្រ័យ ។ នាងដាក់ឈ្មោះសត្វទាំងនោះទាំងពពែទាំងក្ងោកញីឈ្មោល.... អាសុខ ។ ព្រោះសត្វចិញ្ចឹមទាំងនេះផ្ដល់សេចក្ដីសុខដល់ម្ចាស់ផ្ទះមែន ។ ការចិញ្ចឹមសត្វរបស់នាងពុំមែនជាពាណិជ្ជកម្មទេ គឺសម្រាប់ជាលម្អ ។ ភូមិករដ៏ទូលាយមានរុក្ខជាតិស៊ីផ្លែច្រូងច្រាង ផ្ដល់ម្លប់យ៉ាងត្រឈឹងត្រឈៃ ជាទីមនោរម្យដល់សត្វចិញ្ចឹម ។

អាទិត្យមួយ ក្រោយពេលបាយព្រឹករួច ខ្ញុំចុះពីលើផ្ទះជូនម៉ែធ មកមើលនាងនិងម៉ែដោះឱ្យចំណីសត្វ ។ សត្វទាំងអស់

ហាក់មានសេចក្ដីសុខណាស់ ។ ក្រោកស៊ីចំណីផឹកទឹកឆ្អែតស្កប់ស្កល់ហើយ ពួកវាខ្លះជន្លជល់គ្នាលេង ខ្លះហើរឆ្វៀលឆ្វាត់ជុំវិញដំបូល ខ្លះរងាវ បួល ធ្វើកមិកង៉ក់ៗ ។ .... នាងលូកដៃបោសសំអាតខ្លួនប្រាណ ដើរតម្រង់មករកខ្ញុំដែលអង្គុយច្រងុកលើទោងដែក ។

- ម៉េចបងសំឡាញ់ ! មានអារម្មណ៍យ៉ាងណាដែរ !

- រីករាយឥតឧបមា និងមានសង្ឃឹមជានិច្ច ។ ចុះអូនវិញ ? (ខ្ញុំដាក់សំណួរ)

- គឺអូន ! គឺអូន ! គឺអូន ! គឺអូនស្រឡាញ់បង បងស្រឡាញ់អូន ។ អូនស្រឡាញ់បងលើសបងទៀត ។

ខ្ញុំសើចក្នុងបំពង់ក ដោយអារម្មណ៍ត្រជាក់បំផុត ។

- បងជជែកអ្វីក៏មិនឈ្នះអូនដែរ. តែការពិតបងស្រឡាញ់អូនលើសវត្ថុមានតម្លៃនានានៅលើលោកនេះ គ្មានវត្ថុអ្វីមកផ្ទឹមនឹងចិត្តបង ដែលស្រឡាញ់អូនបានទេ !

នាងនៅស្ងៀម យើងនៅស្ងៀមទាំងពីរនាក់ ។

- បង វ៉ាត !

- ...... ! ! (ខ្ញុំនៅស្ងៀម)



នាងអង្រួនខ្ញុំ :

- បង វ៉ាត !

ខ្ញុំយកដៃគៀរសក់នាង បញ្ជាក់ថាខ្ញុំឮពាក្យនាងហៅហើយ. នាងចង់និយាយអីក៏និយាយមកចុះ. ខ្ញុំចាំស្ដាប់ ។

- អូនចង់និយាយច្រើនណាស់ គឺនិយាយពីអ្វីៗក្នុងចិត្តអូន ប្រយោជន៍ឱ្យបងយល់ទាំងអស់នូវអារម្មណ៍អូន តែអូនមិនដឹងចាប់និយាយពីត្រង់ណាមុន. ត្រូវចោលត្រង់ណា ពាក្យត្រង់ណា ព្រោះវាវែងពេក. ធំធេងពេក ....

ខ្ញុំច្របាច់ដៃនាងស្រាលៗ ហើយនិយាយតិចៗ :

- ពុំចាំបាច់អូននិយាយទេ កាយវិការអូនចំពោះបងវាធំធេងណាស់ទៅហើយ ! សព្វថ្ងៃបងបារម្ភតែម្យ៉ាង គឺធ្វើម៉េចឱ្យអូនថ្កើងថ្កាន.....

និយាយដល់ត្រឹមនេះនាងខ្ទប់មាត់ខ្ញុំរួចទះថ្ពាល់ខ្ញុំតិចៗ

- បងឯងនេះព្រើលណាស់! គ្រាន់តែបងស្រឡាញ់អូនដោយស្មោះយ៉ាងនេះ អូនបានថ្កើងថ្កានណាស់ទៅហើយ !

នាងប្រហែលជាមិនយល់ន័យ ដែលខ្ញុំចង់និយាយនោះទេ។ មែន ! ទោះជាក្ដីបារម្ភសុទ្ធសាធរបស់ខ្ញុំ. គឺខ្ញុំខ្លាចតែរក